អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សុន្ទរកថា
ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង ហុយ ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
ថ្លែងក្នុងឱកាសបើកកិច្ចប្រជុំពិគ្រោះយោបល់ស្តីពី
ការរៀបចំនិយាមប្រតិបត្តិដើម្បីជាក់បញ្ចូលការងារឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍
ទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់ និងវិនិយោគឃុំ-សង្កាត់

ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៧

- *ឯកឧត្តម លោកជំទាវ គណៈអធិបតី*
- *លោកស្រី ភ្លាជាំងកា អាន់ដ្រើ ប្រធានអង្គការយូអិនអេដស៍ (UNAIDS) ប្រចាំកម្ពុជា*
- *អស់លោក លោកស្រីជាតំណាងក្រសួង មន្ទីរដែលជាសមាជិករបស់*
  អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- *អ្នកតំណាងដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិល*
- *អ្នកតំណាងប្រជាជនប្រឈមមុខខ្ពស់ និងអ្នកផ្ទុកមេរោគអេដស៍*
- *អស់លោក លោកស្រី នាងកញ្ញា ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ជាទីរាប់អាន*

ជាបឋម តាងនាមអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ដោយបានមកថ្លែងក្នុងពិធីបើក ***កិច្ចប្រជុំពិគ្រោះយោបល់ស្តីពីការរៀបចំនិយាមប្រតិបត្តិដើម្បីជាក់បញ្ចូលការងារឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់ និងវិនិយោគឃុំ-សង្កាត់*** ដ៏មានសារៈសំខាន់នាពេលនេះ។ ជាមួយគ្នានេះ ខ្ញុំសូមថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ដែលអញ្ជើញមកពីក្រសួងមន្ទីរពាក់ព័ន្ធមួយចំនួន និងជាពិសេសតំណាងអាជ្ញាធរដែនដីឃុំ-សង្កាត់ នៃរាជធានីភ្នំពេញព្រមទាំងដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិលអ្នកតំណាងប្រជាជនគន្លឹះ ចូលរួមក្នុងសិក្ខាសាលាដ៏មានសារៈសំខាន់នេះ ។

គោលបំណងនៃកិច្ចប្រជុំពិគ្រោះយោបល់នាថ្ងៃនេះគឺ យើងចង់ប្រមូលយកនូវមតិយោបល់របស់ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីក្នុងការរៀបចំនូវនិយាមប្រតិបត្តិមួយដែលផ្តល់នូវការណែនាំ និងគាំទ្រ ក្នុងការសម្របសម្រួលឱ្យឃុំសង្កាត់អនុវត្តនូវអន្តរាគមន៍ដែលទាក់ទងនឹងមេរោគអេដស៍ និងជំងឺអេដស៍ និងសេវាពាក់ព័ន្ធនានាក្នុងចំណោមប្រជាជនគន្លឹះ និងប្រជាជនទូទៅដែលជា

គោលដៅឱ្យមានប្រសិទ្ធភាព។ ការអនុវត្តនិយាមនេះនឹងជួយពង្រីកតួនាទីរបស់មណ្ឌលសុខភាព សាលាឃុំ-សង្កាត់ និងប៉ុស្តិ៍នគរបាលរដ្ឋបាលដើម្បីចូលរួមក្នុងការលុបបំបាត់មេរោគអេដស៍ និងជំងឺអេដស៍ឱ្យបាននៅឆ្នាំ២០២៥ នៅតាមមូលដ្ឋាននីមួយៗ។

សំណួរសំខាន់សម្រាប់កិច្ចប្រជុំពិគ្រោះយោបល់នេះគឺផ្តោតទៅលើការអនុវត្តវិធីសាស្ត្រ និងនិយាមដែលចង្អុលទិសឱ្យសហគមន៍រកឃើញ និងផ្តល់សេវាដល់ប្រជាជនគន្លឹះ និងប្រជាជនទូទៅដែលជាគោលដៅ (Key Populations and Targeted General Populations) ហើយបង្កើនសេវាឱ្យបានខ្លាំងក្លា និងរក្សាឱ្យអ្នកទាំងនោះនៅបន្តក្នុងសេវាព្យាបាលបានជាប់ជានិច្ច។

ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី!

ខ្ញុំសូមគូសបញ្ជាក់ជូនថា រយៈពេលជាងពីទសវត្សរ៍កន្លងទៅនេះប្រទេសកម្ពុជាយើងបានចលនា និងប្រើប្រាស់ធនធានអស់ប្រមាណជា៨០០លានដុល្លារអាម៉េរិក ដែលភាគច្រើនជាការចំណាយរបស់ដៃគូអភិវឌ្ឍន៍។ តាមតួលេខដែលផ្តល់ឱ្យដោយការគណនាថវិកាចំណាយលើការងារអេដស៍សរុបលើកទី៥ នៅឆ្នាំ២០១៥ (National AIDS Spending Assessment , NASA V) បញ្ជាក់ថា ១៧%នៃថវិកាសរុបចំនួន៤៦លាន៨សែនដុល្លារអាម៉េរិក ជាការរួមចំណែករបស់រាជរដ្ឋាភិបាល។ ដោយមានការវិនិយោគធនធាន៨០០លានដុល្លារអាម៉េរិកនេះ ជាងពីទសវត្សរ៍កន្លងទៅ និងការចូលរួមចំណែកដ៏ធំធេងពីសំណាក់ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ជាតំណាងក្រសួងមន្ទីរ សង្គមស៊ីវិល ប្រជាជនប្រឈមមុខខ្ពស់ និងអ្នកផ្ទុកមេរោគអេដស៍ ព្រមទាំងអាជ្ញាធរដែនដីដែលជាសកម្មជនលើការងារអេដស៍បានបញ្ចៀសមិនឱ្យប្រជាជនខ្មែរយើងចំនួន ៩សែននាក់ឆ្លងមេរោគអេដស៍ និងចំនួនជាង៦សែននាក់ពីការស្លាប់ដោយជំងឺអេដស៍។

ដោយយើងដឹងថាមានប្រជាពលរដ្ឋប្រមាណ១២.០០០នាក់ មិនទាន់បានចូលមកទទួលសេវាថែទាំព្យាបាលនៅឡើយ កិច្ចប្រជុំពិគ្រោះយោបល់នេះ រៀបចំឡើងដើម្បីរៀបចំផែនការយុទ្ធសាស្ត្រសម្រាប់ឱ្យយើងអាចសម្រេចគោលដៅរបស់រាជរដ្ឋាភិបាលក្នុងការបញ្ចប់ការរីករាលដាលជំងឺនេះ ឱ្យបាននៅឆ្នាំ២០២៥ គឺប្រាំឆ្នាំមុនគោលដៅពិភពលោក។ យើងក៏បានដឹងដែរថា ជំនួយពីខាងក្រៅសម្រាប់ការឆ្លើយតបមេរោគអេដស៍ត្រូវបានធ្លាក់ចុះ ស្របពេលដែលស្ថានភាពសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាបានឈានដល់ជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាប។ ប្រការនេះតម្រូវឱ្យប្រទេសកម្ពុជាយើងត្រូវខិតខំពង្រឹងភាពជាម្ចាស់នៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ឱ្យទៅដល់មូលដ្ឋាន ដោយវិនិយោគធនធានក្នុងស្រុកដើម្បីធានាប្រសិទ្ធភាព និងចីរភាពនៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ជាពិសេសក្រោយឆ្នាំ២០២០។

ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី!

ខ្ញុំសូមឆ្លៀតឱកាសដ៏វិសេសវិសាលនេះ ជម្រាបជូនឯកឧត្តម លោកជំទាវ អស់លោក លោកស្រីថា ប្រទេសកម្ពុជាយើងត្រូវបានអង្គការយូអិនអេដស៍ប្រកាសក្នុងកិច្ចប្រជុំអន្តរជាតិ នៅទីក្រុងប៉ារីសនាថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៧ថា ជាប្រទេសមួយក្នុងចំណោមប្រទេសទាំង៧ដែលបានសម្រេចគោល

ដៅ៩០-៩០-៩០។ ភាពជោគជ័យរបស់កម្ពុជាគឺដោយសារតែមានការប្តេជ្ញាចិត្តរួមគ្នាពីសំណាក់រាជរដ្ឋាភិបាលក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងមួយចំណែកដោយមានកិច្ចសហការដ៏ល្អរវាងស្ថាប័នរដ្ឋ និងដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និងប្រជាជនប្រឈមមុខខ្ពស់ និងអ្នកផ្តុំកមេរោគអេដស៍ផងដែរ។

បច្ចុប្បន្ននេះមានអ្នកស្ម័គ្រចិត្តថ្នាក់មូលដ្ឋានប្រមាណ១.៦០០នាក់ ដែលកំពុងបំពេញការងារដោយទទួលបានការគាំទ្រពីមូលនិធិសកល និងUSAID។ អ្នកទាំងនោះកំពុងប្រឈមនឹងការបាត់បង់ការងារ ដោយសារជំនួយពីខាងក្រៅប្រទេសក្នុងការឆ្លើយតបមេរោគអេដស៍ត្រូវបានធ្លាក់ចុះផងដែរ។ ការប្រឹងស្វះស្វែងអ្នកផ្តុំកមេរោគអេដស៍ប្រមាណ១២.០០០ដែលនៅសល់ និងផ្តល់ការថែទាំបន្តដល់អ្នកជំងឺអេដស៍ទូទាំងប្រទេសក៏ជាបន្ទុកមួយចំណែកនៃអ្នកស្ម័គ្រចិត្ត ដែលអាចមានប្រមាណតែ៦០០នាក់ក្នុងរវាងឆ្នាំ២០១៨ដល់២០២០។ បើទោះបីជាយើងបានធ្វើការផ្លាស់ប្តូរយុទ្ធសាស្ត្រថ្មីដែលមានលក្ខណៈផ្តោតលើប្រជាជនគន្លឹះដែលមានភាពប្រឈមខ្លាំង និងតែទៅលើអ្នកជំងឺអេដស៍ដែលមិនទាន់មានលំនឹងក្តី ក៏យើងនៅតែត្រូវការអ្នកស្ម័គ្រចិត្តរហូតដល់ឆ្នាំ២០២៥ ឬ២០៣០ទៀតឯណោះ។ ប្រការដែលគ្មានការធានាពីដៃគូអភិវឌ្ឍន៍ ជាហេតុផលដែលនាំឱ្យយើងមានការគិតគូរលក្ខណៈបុរេសកម្ម(Proactive) ដោយពិនិត្យមើលពីជម្រើស និងលទ្ធភាពដែលអាចឱ្យយើងក្លាយជាម្ចាស់ក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ក្នុងរយៈកាលយូរអង្វែង។

ឆ្លើយទៅនឹងការធានាចីរភាពនៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ខ្ញុំសូមឆ្លៀតឱកាសជម្រាបជូនអង្គប្រជុំអំពីកិច្ចខិតខំប្រឹងប្រែងមួយចំនួនដូចខាងក្រោមនេះ ៖

- តាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រាជរដ្ឋាភិបាលបានឯកភាពផ្តល់ហិរញ្ញប្បទាន៥លាន២សែនដុល្លារអាម៉េរិក ដើម្បីស្របទាញគម្រោងមូលនិធិសកលដែលមានទឹកប្រាក់៤១លាន៦សែនដុល្លារអាម៉េរិកសម្រាប់ឆ្នាំ២០១៨ ដល់២០២០។ លើសពីនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក៏បានទទួលយល់ព្រមដើរតួនាទីដឹកនាំក្នុងយន្តការសម្របសម្រួល និងធ្វើជាអ្នកទទួលជំនួយផ្ទាល់ផងដែរ។
- យុទ្ធសាស្ត្រសុខាភិបាលរបស់ក្រសួងសុខាភិបាល សម្រាប់ឆ្នាំ២០១៦-២០២០បានរៀបចំឡើងក្នុងដំណើរឆ្ពោះទៅកាន់ការផ្តល់សេវាសុខភាពជាសកល (Universal Health Coverage) និងការប្រកាន់យកនូវគោលការណ៍គោរពសិទ្ធិទទួលបានសេវាថែទាំសុខភាពប្រកបដោយសមធម៌សម្រាប់ប្រជាពលរដ្ឋទាំងអស់ជាគុណតម្លៃ។ នៅក្នុងរយៈពេល៥ខែដើមឆ្នាំ២០១៧មានអ្នកជំងឺអេដស៍ចំនួន១៧.៥០០នាក់ បានចុះឈ្មោះក្នុងប្រព័ន្ធកំណត់ត្រាអ្នកជំងឺ ក្នុងមន្ទីរពេទ្យ៤១ដែលទទួលបានកញ្ចប់គាំទ្រមូលនិធិសមធម៌។ សូមបញ្ជាក់ថា រាជរដ្ឋាភិបាលបានរួមចំណែក៥០%នៃថវិកាមូលនិធិសមធម៌សម្រាប់អ្នកជំងឺទូទៅ ក៏ដូចជាអ្នកជំងឺអេដស៍ផងដែរ។
- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងក្រសួងផែនការបានសហការគ្នាចាប់តាំងពីឆ្នាំ២០១៦មកក្នុងការបញ្ចូលគ្រួសាររងផលប៉ះពាល់ដោយសារមេរោគអេដស៍ និងជនងាយរងគ្រោះក្នុងដំណើរការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ។

ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី!

ឆ្លៀតក្នុងពិធីបើកសិក្ខាសាលានេះ ខ្ញុំសូមអំពាវនាវចំពោះ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីទាំងអស់ធ្វើការពិចារណារលើសំណួរគន្លឹះមួយចំនួនដូចខាងក្រោមនេះ ៖

១) តើឃុំ-សង្កាត់បានទទួលដឹងពីមុខនាទី ម្ចាស់ការលើការបញ្ចប់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ឱ្យបាននៅឆ្នាំ២០២៥ហើយឬនៅ?

២) តើឃុំ-សង្កាត់មានសមត្ថភាព(ចំណេះដឹង)គ្រប់គ្រាន់ ក្នុងការបញ្ចប់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ឱ្យបាននៅឆ្នាំ២០២៥ដែរឬទេ?

៣) តើឃុំ-សង្កាត់មានថវិកាសមស្របក្នុងបញ្ចប់ការរីករាលដាលជំមេរោគអេដស៍/ជំងឺអេដស៍ឱ្យបាននៅឆ្នាំ២០២៥ដែរឬទេ?

៤) តើឃុំ-សង្កាត់ត្រូវសហការជាមួយស្ថាប័នណាខ្លះ និងយ៉ាងដូចម្តេចដើម្បីបញ្ចប់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ឱ្យបាននៅឆ្នាំ២០២៥?

សូមឯកឧត្តម លោកជំទាវ លោក លោកស្រីប្រែក្លាយចំណេះដឹងដែលបានទទួលពីវេទិកាដ៏សំខាន់នេះ ឱ្យទៅជាកិច្ចសហការរវាងអាជ្ញាធរដែនដី ក្រុមគ្រូពេទ្យ អ្នកស្ម័គ្រចិត្តថ្នាក់ភូមិឃុំសម្រាប់មេរោគអេដស៍ បណ្តាញស្ត្រី និងកុមារ និងក្រុមអង្គការក្រៅរដ្ឋាភិបាលដែលបម្រើការងារអេដស៍ឱ្យបានកាន់តែល្អប្រសើរឡើង សំដៅបញ្ចប់ការរីករាលដាលជំងឺអេដស៍ឱ្យបាននៅឆ្នាំ២០២៥ នៅក្នុងមូលដ្ឋានរបស់យើង។

លើសពីនេះទៅទៀត សូមឱ្យកិច្ចសហការនេះអាចរក្សាបាននូវការសម្ងាត់ស្តីពី ស្ថានភាពផ្ទុកមេរោគអេដស៍នៃពលរដ្ឋគ្រប់រូបដែលបានឆ្លងមេរោគនេះផងដែរ។ ប្រការនេះអាចឱ្យឃុំសង្កាត់ចៀសវាងបាននូវការរើសអើងដែលជារំលោភលើសិទ្ធិអ្នកដែលរងគ្រោះដោយជំងឺអេដស៍។

ជាទីបញ្ចប់នេះ ខ្ញុំសូមថ្លែងអំណរគុណ និងកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ឯកឧត្តម លោកជំទាវ លោក លោកស្រី ទាំងអស់ដែលមានវត្តមានក្នុងសិក្ខាសាលានេះ។ ខ្ញុំសូមប្រសិទ្ធពរជូន ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ និងអង្គពិធីទាំងមូលសូមទទួលបានជោគជ័យ និងសម្រេចទៅតាមគោលបំណងដែលបានគ្រោងទុក និងសូមប្រកបដោយពុទ្ធពរទាំង៤ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ខ្ញុំសូមប្រកាសបើក ***កិច្ចប្រជុំពិគ្រោះយោបល់ស្តីពី ការរៀបចំនិយាមប្រតិបត្តិដើម្បីជាក់បញ្ចូលការងារឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់ និងវិនិយោគឃុំ-សង្កាត់*** ចាប់ពីពេលនេះតទៅ។

សូមអរគុណ!